**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ៧២៥៩ ព.ណ.ភ.ស.ប

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

**ជម្រាបមក**
**លោក/លោកស្រីប្រធានក្រុមហ៊ុន ស៊ីណាត្រា អ៊ិនធើណេសិនណល**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្រាម៉ាក **"JACK DANIEL'S"**  **"JACK DANIEL"**  និង  ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ស៊ីណាត្រា អ៊ិនធើណេសិនណល** ។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ស៊ីណាត្រា អ៊ិនធើណេសិនណល** ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន JACK DANIEL'S PROPERTIES, INC ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥៤៩២/៩៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥៤៩៣/៩៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៤៩៩១៨/១៤ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៥៤៩៦/១០ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២៥០៩៨/០៦ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្រាពាក់ម៉ាកខាងលើ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ស៊ីណាត្រា អ៊ិនធើណេសិនណល** ដែលទទួលបានពីក្រុមហ៊ុន JACK DANIEL'S PROPERTIES, INC ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ មានសុពលភាពត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន JACK DANIEL'S PROPERTIES, INC ដែលជាម្ចាស់ម៉ាក ។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ,ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sankat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ: (៨៥៥) -២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

ចាប់ពីរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានរារាំងចំពោះទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចក្នុងរយៈពេល ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

អ៊ុក ប្រាជ្ញា

ចម្លងជូន:
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ